គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១៤ ចេញផ្សាយថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១
No. 14 Released on October 04, 2021

# អត្ថបទប្រចាំសប្តាហ៍ | Weekly Article

## បរធនបាលជំនួស | Substitute Trustee


រូបភាព | Picture: https://info.legalzoom.com/sites/lz.com/files/AdobeStock_287065506.jpg

បរធនបាល អាចត្រូវបានជំនួសដោយបុគ្គលផ្សេងទៀតតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ ករណីដែលគ្មានចែងអំពីលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងប្រយោគខាងដើម បរធនបាលត្រូវបានជំនួសតាមលក្ខខណ្ឌដូចជា÷ **(១)** បើបរធនបាលជារូបវន្តបុគ្គល បរធនបាលនេះត្រូវបានជំនួស **(ក)** ជាស្វ័យប្រវត្តិ នៅពេលដែលខ្លួនទទួលមរណភាព អសមត្ថភាពផ្លូវកាយឬផ្លូវចិត្ត ត្រូវបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចថាក្ស័យធន ប្រព្រឹត្តបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ឬតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយបទប្បញ្ញត្តិជាធរមានរបស់និយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** / បញ្ញត្តិករពាក់ព័ន្ធ។**(ខ)** តាមសេចក្តីសម្រេចភាគច្រើនដាច់ខាតរបស់បរធនបាលទាំងអស់ នៅពេលដែលបរធនបាលចូលនិវត្តន៍ ឬបដិសេធមិនបំពេញការងារ ឬមិនសក្តិសមបំពេញការងារ។**(២)** បើបរធនបាលជានីតិបុគ្គលបរធនបាលនេះ ត្រូវបានជំនួសនៅពេលដែលបរធនបាល បញ្ឈប់សកម្មភាពរបស់ខ្លួន ហើយត្រូវបានជម្រះបញ្ជី ឬត្រូវបានរំលាយ។

**ន.ប.ធ.** / បញ្ញត្តិករពាក់ព័ន្ធជាអ្នកចេញសេចក្តីសម្រេចតែងតាំងបរធនបាលជំនួស។ ករណីបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាលជំនួស, បរធនបាលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **ន.ប.ធ.**។ ការជំនួសបរធនបាល អាចធ្វើបានលុះត្រាតែមានចែងលក្ខខណ្ឌ និងនីតិវិធីជំនួសបរធនបាលនៅក្នុងលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន *(ច្បាប់ស្តីពីបរធនបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១)*។

A trustee may be replaced by another person in accordance with the conditions and procedures set forth in the trust instrument or the provisions in force. In cases where there is no provision for the conditions and procedures as stated in the first sentence, the trustee shall be substituted by the following conditions: **(1)** If the trustee is a physical person, the trustee is **(a)** automatically replaced when he/she dies, the physical or mental incapacity, is declared by the competent authority as a bankrupt, a misdemeanor or a felony or other condition determined by the provisions in force of the Trust Regulator **(TR)**/ relevant regulators. **(b)** by an absolute majority decision of all the trustees when the trustee retires or refuses to perform his/her duties or he/she is not fit to perform the duties. **(2)** If the trustee is a legal entity, the trustee is replaced when the trustee ceases to be active and is cleared or dissolved.

The **TR**/ relevant regulator is the one who issues the decision to appoint the substitute trustee. In case the relevant regulator appoints a substitute trustee, the trustee shall notify in writing to the **TR**. The substitution of the trustee can be done only if the conditions and procedures for the substitution of the trustee are stated in the trust instrument or the regulations in force *(Law on Trust, 2019; Law on the Organization and Functioning of the Non-Bank Financial Services Authority, 2021)*.

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- មាត្រា២៥, ច្បាប់ស្តីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.